# បញ្ហានៅផ្ទះជួលរបស់កម្មករ

លំនាំបទៈ ព្រៃល្បាស់ទៀវទី

១ ធម្មជាតិទៀវទីគាប់ផ្ទៃមេឃា សុរិយាយាងរះប៉ប្រះចុងព្រៃ
អ្នករះចែងចាំងបញ្ចេញរស្មី អ្នកគ្មានទុក្ខអ្វីខ្វល់ដូចខ្ញុំឡើយ ។

២ ចំនែករូបខ្ញុំពិបាកខ្លាំងណាស់ ព្រោះតែម្ចាស់ផ្ទះគ្មានចិត្តមេត្តា
តំឡើងថ្លៃទឹកភ្លើងតាមចិន្តា ចំណែកសេវាក៏មិនល្អដែរ ។

បន្ទរ១ រីឯបន្ទប់ក៏តូចចង្អៀត ថែមមនុស្សចូលទៀតហើយតំឡើងប្រាក់
មិនគិតខ្វល់ថាកម្មករលំបាក គេគិតតែប្រាក់ចូលហោប៉ៅប៉ុណ្ណោះ ។

៣ យើងធ្វើការបានប្រាក់ខែតិចណាស់ ៣០ដុល្លាព្រោះខ្ញុំចូលថ្មី
បើឡើងយ៉ាងនេះតើខ្ញុំសល់អ្វី ផ្ញើរជូនម្តាយថ្លៃផ្គត់ផ្គង់គ្រួសារ ។

បន្ទរ២ ពេលដល់ខែបង់លុយឈ្នួលមិនគ្រប់ ម្ចាស់ផ្ទះនឹងកត់រួចយកការប្រាក់
ទ្វេរមួយជាពីរមិនបាច់តវ៉ា ដល់ខែកាលណាទារមិនអោយខ្វះ ។

៤ ព្រោះខ្ញុំកម្មករមកពីជនបទ ម្ចាស់ផ្ទះសន្មត់ថាខ្ញុំមិនល្អ
មិនឲ្យកូនមកនិយាយតបត ជាមួយកម្មករស្រីដូចពួកខ្ញុំ ។


កម្មវិធីកម្មកររោងចក្រកាត់ដេរ ©២០០៥

និពន្ធនិងច្រៀងដោយកម្មកររោងចក្រកាត់ដេរ